# រដ្ឋាភិបាលឌីជីថលនៅកម្ពុជា

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ រដ្ឋាភិបាលនៃបណ្តាប្រទេសនានាជុំវិញពិភពលោក បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលសាធារណៈ និងសេចក្តីសម្រេចនានា។ ជាក់ស្តែង ស្ទើរគ្រប់ប្រទេសទាំងអស់បានអភិវឌ្ឍន៍រដ្ឋាភិបាលឌីជីថល ដែលក្នុងនោះ **៦៥%** មានសន្ទស្សន៍អភិវឌ្ឍន៍រដ្ឋាភិបាលឌីជីថលខ្ពស់ នេះបើយោងតាមអង្គការសហប្រជាជាតិ។ យោងតាម **«គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥»** រដ្ឋាភិបាលឌីជីថលសំដៅដល់ការធ្វើទំនើបកម្ម និងសមាហរណកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាល និងសេវាសាធារណៈ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងបម្រើសេវាសាធារណៈ ឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋ ដោយយុត្តិធម៌ សមធម៌ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្ន។ ខាងក្រោមនេះជាប្រភេទសំខាន់ៗនៃរដ្ឋាភិបាលឌីជីថល រួមមាន៖

- **រដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ (Government to Citizen-G2C)៖** សំដៅដល់ការផ្តល់ព័ត៌មាន ឬសេវាកម្ម ដូចជា សេវាអត្រានុកូលដ្ឋាន, សេវានីត្យានុកូលកម្ម, ការធ្វើលិខិតឆ្លងដែន, ការចុះបញ្ជីយានយន្ត, ការចុះបញ្ជីអាជីវកម្ម និងការចុះបញ្ជីកម្មសិទ្ធិដី ឬផ្ទះជាដើម ដល់ប្រជាពលរដ្ឋតាមថ្នាលឌីជីថល។ ការណ៍នេះ អាចជួយឱ្យរដ្ឋាភិបាលរក្សាទំនាក់ទំនងបានយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋ ព្រមទាំងអាចផ្តល់ភាពងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការនានារបស់ពួកគេ។

- **រដ្ឋាភិបាលទៅកាន់អាជីវកម្ម (Government to Business-G2B)៖** សំដៅដល់ការផ្លាស់ប្តូរសេវាកម្មទៅវិញទៅមករវាងរដ្ឋាភិបាល និងអាជីវករតាមថ្នាលឌីជីថល។ រដ្ឋាភិបាលអាចប្រើប្រាស់ថ្នាលឌីជីថលដើម្បីផ្តល់ព័ត៌មាន ដូចជា ព័ត៌មានថ្មីៗទាក់ទងនឹងអាជីវកម្ម, គោលនយោបាយ និងច្បាប់បានទាន់ពេលវេលាដល់អាជីវករ ព្រមទាំងអាចជួយឱ្យអាជីវករមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវា ដូចជា ការធ្វើ ឬបន្តអាជ្ញាប័ណ្ណ, ការចុះឈ្មោះអាជីវកម្ម និងការបង់ពន្ធជាដើម។ ការណ៍នេះ អាចជួយពង្រឹងទំនាក់ទំនងរវាងរដ្ឋាភិបាល និងអាជីវករ ព្រមទាំងពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពការងារដែលអាចជួយដល់ការអភិវឌ្ឍអាជីវកម្មរបស់ពួកគេ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលក៏អាចទទួលបានសេវាពីអាជីវករ តាមរយៈការអនុញ្ញាតឱ្យអាជីវករតូចធំធ្វើការដេញថ្លៃសម្រាប់គម្រោងនានា ដែលអាចជួយឱ្យរដ្ឋាភិបាលសន្សំសំចៃថវិកាបានច្រើន។

**រដ្ឋាភិបាលទៅកាន់រដ្ឋាភិបាល (Government to Government-G2G)៖** សំដៅដល់ការសម្រួលដល់ការចែករំលែកទិន្នន័យ និងអន្តរកម្មរវាងស្ថាប័នរដ្ឋតាមអនឡាញ ដែលអាចជួយឱ្យការងាររបស់រដ្ឋាភិបាលដំណើរការបានលឿន និងមានប្រសិទ្ធភាពជាងមុន ព្រមទាំងជួយពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល ទាំងក្នុងកម្រិតតំបន់ និងសកល។

**រដ្ឋាភិបាលទៅកាន់មន្ត្រី (Government to Employee-G2E)៖** សំដៅដល់ការផ្តល់ភាពងាយស្រួលដល់មន្ត្រីគ្រប់ជាន់ថ្នាក់ក្នុងការទទួលបានព័ត៌មានតាមអនឡាញ ដូចជា គោលនយោបាយសុខុមាលភាព, ការបណ្តុះបណ្តាល និងច្បាប់ស្តីពីការងារ ព្រមទាំងការសុំឈប់សម្រាកប្រចាំឆ្នាំ, ការពិនិត្យមើលប្រាក់បៀវត្ស និងប្រាក់សោធននិវត្តន៍, ការពិនិត្យសមតុល្យការឈប់សម្រាកជាដើមតាមអ៊ីនធឺណិត។ ការណ៍នេះអាចជួយពង្រឹងទំនាក់ទំនងរវាងស្ថាប័នរដ្ឋ និងមន្ត្រី, ពន្លឿនដំណើរការការងារ ព្រមទាំងពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពការងារ។

ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជំរុញកំណែទម្រង់ក្រសួងស្ថាប័ន និងរដ្ឋាភិបាលថ្នាក់ក្រោមជាតិ, បង្កើតបរិយាកាសអំណោយផលដល់ការធ្វើអាជីវកម្ម និងជួយឱ្យការផ្តល់សេវារបស់រដ្ឋាភិបាលស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងអាជីវករកាន់តែប្រសើរ។ ហេតុនេះហើយ យោងតាមអង្គការសហប្រជាជាតិ រដ្ឋាភិបាលជុំវិញពិភពលោក រួមទាំងកម្ពុជា បាន និងកំពុងបន្តអភិវឌ្ឍន៍រដ្ឋាភិបាលឌីជីថលជាលំដាប់ ដែលជាហេតុធ្វើឱ្យតម្លៃមធ្យមនៃសន្ទស្សន៍អភិវឌ្ឍន៍រដ្ឋាភិបាលឌីជីថលនៅប្រទេសចំនួន ១២៦ បានកើនឡើងពី **0,៥៥** នៅឆ្នាំ ២០១៨ ដល់ **0,៦** នៅឆ្នាំ ២០២០ ដែលក្នុងនោះប្រទេសកម្ពុជាជាប្រទេសមួយដែលមានការអភិវឌ្ឍរដ្ឋាភិបាលប្រសើរជាងគេក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែង យោងតាម **លោកស៊ុន វ៉ាពីជ** អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ កម្ពុជាមានអត្រានៃការវិនិយោគលើរដ្ឋាភិបាលឌីជីថលច្រើនជាងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត និងប្រទេសមួយចំនួនក្នុងតំបន់អាស៊ាន ដូចជា ឡាវ និងមីយ៉ាន់ម៉ា រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតលើការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលតាំងពីឆ្នាំ ២000 មកម្ល៉េះ ដោយបានបង្កើតនូវអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (NiDa)។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលនៅតែបន្តការយកចិត្តទុកដាក់លើការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដោយបានផ្តល់នូវសេវានានាតាមប្រព័ន្ធអនឡាញ និងបង្កើតនូវ **«គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥»** ដើម្បីអាចរក្សាភាពប្រកួតប្រជែងស្របពេលនៃការមកដល់នៃបដិវត្តន៍ឧស្សាហកម្ម ៤.0 និងវិបត្តិជំងឺកូវីដ-១៩។

## I. បច្ចេកវិទ្យាដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលនៅកម្ពុជា

រដ្ឋាភិបាលនៃបណ្តាប្រទេសនានាជុំវិញពិភពលោក រួមទាំងកម្ពុជា បាននិងកំពុងធ្វើបដិវត្តកម្មឌីជីថលលើការផ្តល់សេវា និងដំណើរការងារ ដើម្បីអាចផ្តល់សេវាដល់ប្រជាពលរដ្ឋបានកាន់តែប្រសើរ និងបំពេញការងារប្រកបដោយស័ក្តិសិទ្ធិភាព។ ខាងក្រោមនេះជាបច្ចេកវិទ្យាសំខាន់ៗមួយចំនួនដែលត្រូវបានប្រើប្រាស់ក្នុងរដ្ឋាភិបាលឌីជីថល រួមមាន៖

**បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (Information and Communications Technology)៖** យោងតាមគេហទំព័រ DATAREPORTAL គិតត្រឹមដើមឆ្នាំ ២០២២ អ្នកប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជាមានចំនួនប្រមាណ **១៣,៤៤លាននាក់** និងប្រើប្រាស់បណ្តាញសង្គមមានចំនួនប្រមាណ **១២,៦លានគណនី**។ ទន្ទឹមនឹងនេះ យោងតាម **«គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥»** គិតត្រឹមឆ្នាំ២០២១ យុវជនប្រមាណ **៣៧%** អាចចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបានលឿន ហើយបច្ចុប្បន្ននេះ អាជីវករដែលចេះចាប់យកសក្តានុពលពីបច្ចេកវិទ្យាឌីជីថល និងក្រុមហ៊ុនផ្តល់សេវាបច្ចេកវិទ្យាឌីជីថលមានការកើនឡើងជាលំដាប់។ ស្របពេលដែលប្រជាពលរដ្ឋ និងអាជីវករកាន់តែច្រើនចេះទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យា រាជរដ្ឋាភិបាលកម្ពុជាគួរបន្តប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដើម្បីអាចផ្តល់សេវាកាន់តែប្រសើរដល់ពួកគេ។ ជាក់ស្តែង មុនពេលមានវត្តមាននៃបច្ចេកវិទ្យានេះ ប្រជាពលរដ្ឋ និងអាជីវករត្រូវធ្វើដំណើរទៅក្រសួង ស្ថាប័នរដ្ឋាភិបាល ដោយផ្ទាល់ ដើម្បីសាកសួរព័ត៌មាន និងទទួលសេវានានា ដែលធ្វើឱ្យខាតបង់ពេលវេលា និងថវិកាក្នុងការធ្វើដំណើរ។ ប៉ុន្តែ បច្ចុប្បន្ននេះ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដូចជា ទូរស័ព្ទ, គេហទំព័រ, កម្មវិធីទូរស័ព្ទ, បណ្តាញសង្គម និងអ៊ីម៉ែលជាដើម បានអនុញ្ញាតឱ្យប្រជាពលរដ្ឋ និងអាជីវករសាកសួរព័ត៌មាន និងទំនាក់ទំនងជាមួយរដ្ឋាភិបាលបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ព្រមទាំងជួយឱ្យការងាររបស់អាជីវករមានភាពរលូនជាងមុន។ មិនតែប៉ុណ្ណោះ បច្ចេកវិទ្យានេះក៏ជួយឱ្យការចែករំលែកព័ត៌មានបានលឿន និងពង្រឹងទំនាក់ទំនងរវាងស្ថាប័នរដ្ឋ ដែលអាចជួយឱ្យដំណើរការការងារកាន់តែមានប្រសិទ្ធភាព និងផលិតភាពផងដែរ។



**Quick Response Code - QR Code៖** QR Code ផ្តល់ភាពងាយស្រួលដល់រដ្ឋាភិបាលក្នុងការផ្សព្វផ្សាយព័ត៌មាន និងប្រមូលមតិកែលម្អ ព្រមទាំងអាចជួយឱ្យប្រជាពលរដ្ឋ និងអាជីវករអាចចុះឈ្មោះដើម្បីស្នើសុំសេវានានាបានលឿន និងងាយស្រួល។ ជាក់ស្តែង ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានដាក់ចេញកម្មវិធី QR Code «Stop Covid» នៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន, ភោជនីយដ្ឋាន, សណ្ឋាគារ និងរោងចក្រជាដើម ដើម្បីអាចឱ្យសាធារណជនស្កេននៅពេលចូលទីតាំងដែលមានមនុស្សចេញ-ចូលច្រើន ហើយអាចទទួលបានដំណឹងឆាប់រហ័ស ប្រសិនបើទីតាំងនោះ មានករណីឆ្លងជំងឺកូវីដ-១៩។



**ការទូទាត់តាមបែបឌីជីថល (Digital Payment)៖** រដ្ឋាភិបាលអាចទាញយកផលប្រយោជន៍ពីការទូទាត់តាមបែបឌីជីថល ដើម្បីអាចផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងអាជីវករក្នុងការទូទាត់ថ្លៃសេវានានាបានលឿន, សន្សំសំចៃពេលវេលា និងថវិកាក្នុងការធ្វើដំណើរ និងបង្កើនសុវត្ថិភាព។ ជាឧទាហរណ៍ ក្រសួងសាធារណការ និងដឹកជញ្ជូនទទួលយកការទូទាត់តាមឌីជីថលនូវសេវា ដូចជាការចុះបញ្ជីយានយន្ត, ការត្រួតពិនិត្យយានយន្ត, ការស្នើសុំអាជ្ញាប័ណ្ណ និងថ្លៃពន្ធ តាមរយៈការសហការជាមួយក្រុមហ៊ុនក្នុងស្រុក ដូចជា Pi Pay, Wing និង DataPay ជាដើម ដើម្បីផ្តល់ភាពងាយស្រួលជាងមុនដល់ប្រជាពលរដ្ឋ និងអាជីវករ។



**បច្ចេកវិទ្យាកុំព្យូទ័រក្លោដ (Cloud Computing)៖** បច្ចេកវិទ្យាកុំព្យូទ័រក្លោដក៏មានសារៈសំខាន់សំរាប់រដ្ឋាភិបាល ព្រោះបច្ចេកវិទ្យានេះអនុញ្ញាតឱ្យមន្ត្រីធ្វើការរួមគ្នាបានយ៉ាងងាយស្រួល គ្រប់ពេលវេលា និងគ្រប់ទីកន្លែងដែលមានអ៊ីនធឺណិត និងមានតម្លៃសមរម្យ។ លើសពីនេះទៀត បច្ចេកវិទ្យានេះក៏អាចបង្កើនសុវត្ថិភាពទិន្នន័យ ឬព័ត៌មានសំខាន់នានាពីការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត ព្រមទាំងការពារពីការបាត់បង់ ដែលអាចបណ្ដាលមកពីការខូចខាតផ្នែករឹង (Hardware Failure) ផងដែរ។



**ទិន្នន័យធំ (Big Data)៖** រដ្ឋាភិបាលអាចប្រមូលទិន្នន័យបានយ៉ាងច្រើនពីសកម្មភាពការងារប្រចាំថ្ងៃ ដូចជា ការគ្រប់គ្រងប្រព័ន្ធជំនួយសង្គម, ការប្រមូលពន្ធ, ការពិនិត្យមើលដំណើរការប្រព័ន្ធសុខាភិបាល និងអប់រំ និងការកត់ត្រាទិន្នន័យចរាចរណ៍ជាដើម ដែលទិន្នន័យទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយឱ្យសេវារបស់រដ្ឋាភិបាលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបានកាន់តែប្រសើរ។ ទន្ទឹមនឹងនេះ ទិន្នន័យធំក៏អាចជួយឱ្យការប្រើប្រាស់ធនធានកាន់តែមានស័ក្តិសិទ្ធិភាព និងធ្វើឱ្យប្រសើរឡើងនូវសេចក្ដីសម្រេចនានារបស់រដ្ឋាភិបាល។



**ស្វ័យប្រវត្តិកម្ម (Automation)៖** ស្វ័យប្រវត្តិកម្មអាចជួយសម្រួលដល់ដំណើរការការងាររបស់រដ្ឋាភិបាល និងពង្រឹងការផ្តល់សេវាដល់ប្រជាពលរដ្ឋ តាមរយៈការកាត់បន្ថយកំហុស, ពន្លឿនដំណើរការការងារ និងជួយឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់មានពេលគ្រប់គ្រាន់ក្នុងការផ្តោតលើការងារសំខាន់ៗ។ ជាក់ស្តែង រដ្ឋាភិបាលអាចទាញយកសក្តានុពលពីបច្ចេកវិទ្យា Chatbot ដើម្បីអាចឆ្លើយតបទៅកាន់សំណួរនានារបស់ប្រជាពលរដ្ឋ និងអាជីវករបានភ្លាមៗគ្រប់ពេលវេលា។




## II. សារៈសំខាន់ និងអត្ថប្រយោជន៍នៃការអនុវត្តរដ្ឋាភិបាលឌីជីថលនៅកម្ពុជា

បច្ចេកវិទ្យាក្នុងបដិវត្តន៍ឧស្សាហកម្ម ៤.០ ដូចជា បញ្ញាសិប្បនិម្មិត, ប្លុកឆេន, ទិន្នន័យធំ និងប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងលើវិស័យអប់រំ, ទីផ្សារការងារ, វិស័យសុខាភិបាល, វិស័យធុរកិច្ច និងរដ្ឋបាលសាធារណៈជាដើម។ មិនតែប៉ុណ្ណោះ វិបត្តិនៃជំងឺកូវីដ-១៩ បានជំរុញឱ្យបណ្តាប្រទេសនានា រួមទាំងកម្ពុជា ប្រើប្រាស់បច្ចេកវិទ្យា ដើម្បីអាចបន្តសកម្មភាពការងារ, ផ្សារភ្ជាប់ទំនាក់ទំនង, បង្កើនផលិតភាព និងប្រសិទ្ធភាពការងារនានា និងឆ្លើយតបនឹងវិបត្តិនេះប្រកបដោយប្រសិទ្ធភាព។ ហេតុនេះហើយ ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយឱ្យរដ្ឋាភិបាលដើរទាន់សម័យកាលបដិវត្តកម្មឌីជីថល និងឆ្លើយតបនឹងវិបត្តិនានាបានប្រកបដោយប្រសិទ្ធភាព។ ខាងក្រោមនេះជាអត្ថប្រយោជន៍សំខាន់ៗមួយចំនួននៃការអនុវត្តរដ្ឋាភិបាលឌីជីថលនៅកម្ពុជា រួមមាន៖

**ពង្រឹងការផ្តល់សេវាដល់ប្រជាពលរដ្ឋ និងអាជីវករ៖** ជាមួយនឹងរដ្ឋាភិបាលឌីជីថល ប្រជាពលរដ្ឋ និងអាជីវករអាចសាកសួរព័ត៌មាន និងទទួលបានសេវា បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ដែលអាចជួយលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ និងសម្រួលដល់ការធ្វើអាជីវកម្ម។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលក៏អាចទទួលបានមតិកែលម្អ និងអាចប្រមូលទិន្នន័យពីថ្នាលឌីជីថល ដូចជា បណ្តាញសង្គម គេហទំព័រ និងកម្មវិធីទូរស័ព្ទជាដើម ដែលទិន្នន័យទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយឱ្យសេវារបស់រដ្ឋាភិបាលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបានកាន់តែប្រសើរ។

**សន្សំសំចៃថវិកា៖** បច្ចេកវិទ្យា ដូចជា អ៊ីនធឺណិត កុំព្យូទ័រ ទូរស័ព្ទ និងថេប្លេតជាដើម បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយកាត់បន្ថយការចំណាយលើសម្ភារៈការិយាល័យ, ការបោះពុម្ពឯកសារ និងការធ្វើដំណើរ ដើម្បីបញ្ជូនព័ត៌មាន ឬឯកសារដល់ស្ថាប័ននានាដោយផ្ទាល់។ មិនតែប៉ុណ្ណោះ ទិន្នន័យធំអាចជួយឱ្យរដ្ឋាភិបាលគ្រប់គ្រងធនធានហិរញ្ញវត្ថុបានកាន់តែប្រសើរ និងអាចជួយឱ្យរដ្ឋាភិបាលដឹងពីផ្នែកណាដែលគួរចំណាយ ដើម្បីកាត់បន្ថយការចំណាយមិនចាំបាច់។

**ជួយពង្រឹងប្រសិទ្ធភាព និងផលិតភាពការងារ៖** បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយពង្រឹងទំនាក់ទំនងរវាងស្ថាប័ន និងជួយសម្រួលដល់ការចែករំលែកទិន្នន័យដែលធ្វើឱ្យដំណើរការការងារប្រព្រឹត្តទៅបានរលូនជាងមុន។

**ពង្រឹងតម្លាភាព និងភាពបើកចំហ៖** រដ្ឋាភិបាលឌីជីថលពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយពង្រឹងតម្លាភាព និងភាពបើកចំហ ព្រោះប្រជាពលរដ្ឋ ម្ចាស់អាជីវកម្ម និងស្ថាប័ននានាអាចទាញយកទិន្នន័យ និងព័ត៌មានរបស់រដ្ឋាភិបាលបាននៅលើថ្នាល ដូចជា គេហទំព័រ កម្មវិធីទូរស័ព្ទ និងបណ្តាញសង្គមបានយ៉ាងងាយស្រួល។ ការណ៍នេះ អាចជួយឱ្យប្រជាពលរដ្ឋ និងអាជីវករអាចដឹងពីសេចក្តីសម្រេចនានា, ទទួលបានដំណឹងពីសេវារបស់រដ្ឋាភិបាល និងយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនបានកាន់តែប្រសើរ។

**ការពារទិន្នន័យ និងព័ត៌មានសំខាន់៖** បច្ចុប្បន្ននេះ ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតបាននិងកំពុងក្លាយជាបញ្ហាប្រឈមមួយរបស់ប្រជាពលរដ្ឋ អាជីវករ រួមទាំងរដ្ឋាភិបាលផងដែរ។ ក្នុងន័យនេះ ការប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រក្លោដពិតជាមានសារៈសំខាន់ណាស់ក្នុងការរក្សាទិន្នន័យ ឬព័ត៌មានបានយ៉ាងមានសុវត្ថិភាព ព្រោះ ជាទូទៅ ក្រុមហ៊ុនផ្គត់ផ្គង់បច្ចេកវិទ្យានេះចំណាយធនធានច្រើនក្នុងការវិនិយោគលើសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតនេះ។ មិនតែប៉ុណ្ណោះ បច្ចេកវិទ្យានេះក៏អាចការពារទិន្នន័យ ឬព័ត៌មានរបស់រដ្ឋាភិបាលពីការបាត់បង់ ដែលអាចបណ្តាលមកពីការខូចខាតផ្នែករឹងផងដែរ។

## III. កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលនៅកម្ពុជា

បើទោះបីជាការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលនៅកម្ពុជាមានភាពល្អប្រសើរ តែកម្ពុជានៅតែជួបប្រទះបញ្ហាប្រឈម មួយចំនួន ដូចជា កង្វះធនធានមនុស្ស កង្វះហេដ្ឋារចនាសម្ព័ន្ធឌីជីថល ហើយការការពារសន្តិសុខឌីជីថលនៅតាមក្រសួង ស្ថាប័ននៅមានកម្រិតទាប ដែលជាហេតុនាំឱ្យរាជរដ្ឋាភិបាលកម្ពុជាចេញនូវគោលនយោបាយ និងសកម្មភាពនានាក្នុងការលើកកម្ពស់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលជាបន្តបន្ទាប់។ ខាងក្រោមនេះជាកិច្ចខិតខំប្រឹងប្រែងសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលនៅកម្ពុជា រួមមាន៖

**គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥៖** ការរៀបចំគោលនយោបាយរដ្ឋាភិបាលឌីជីថលគឺជាការចាំបាច់ និងបន្ទាន់ សំដៅដោះស្រាយបញ្ហាប្រព័ន្ធព័ត៌មានឌីជីថល ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ អភិបាលកិច្ចទិន្នន័យ និងមូលធនមនុស្ស ដើម្បីជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ច និងសង្គមឱ្យមានភាពស៊ីចង្វាក់គ្នា។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ **«គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥»** កាលពីខែមករា ឆ្នាំ២០២២ ក្នុងគោលបំណងកសាងរដ្ឋាភិបាលឆ្លាត ដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាឌីជីថលជាប្រព័ន្ធអេកូឡូស៊ី សម្រាប់ការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច និងការកែទម្រង់លើគ្រប់វិស័យ ប្រកបដោយតម្លាភាព និងភាពទុកចិត្ត សំដៅបង្កើតបរិយាកាសអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល ប្រកបដោយបរិយាបន្ន តាមរយៈគោលដៅជាយុទ្ធសាស្ត្រ ដូចជា៖

- ការរៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល
- ការរៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ
- ការរៀបចំ និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេវាប្រៃសណីយ៍
- ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល
- ការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និងសេវាសាធារណៈ
- ការកសាងមូលធនមនុស្សឌីជីថល
- ការលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល
- ការរៀបចំកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល
- ការលើកកម្ពស់ធុរកិច្ចឌីជីថល

**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥៖** រដ្ឋាភិបាលឌីជីថលជាតួអង្គដែលត្រូវការជាចាំបាច់ក្នុងការរៀបចំសេដ្ឋកិច្ច និងសង្គមឌីជីថល ឬក៏មានន័យថារាជរដ្ឋាភិបាលត្រូវឈានមុខគេក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ម៉្យាងដើម្បីបង្កើតឱ្យមានតម្រូវការផ្ទាល់ និងម៉្យាងទៀតដើម្បីឱ្យធុរជន និងប្រជាពលរដ្ឋ ចាប់យកវិស័យឌីជីថល។ ដូច្នេះ ដើម្បីជំរុញរបៀបវីរៈនៃការកែទម្រង់របស់រាជរដ្ឋាភិបាល ដោយប្រើប្រាស់បច្ចេកវិទ្យា និងបង្កើតបរិយាកាសប្រកបដោយបរិយាបន្នមួយ ក្នុងការអភិវឌ្ឍ និងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល នៅក្នុង **«ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** រាជរដ្ឋាភិបាលបានផ្តោតទិដ្ឋភាព ៣ សម្រាប់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល រួមមាន រដ្ឋាភិបាល និងសេវាសាធារណៈឌីជីថល តាមរយៈការបន្តផ្តល់ភាពជាម្ចាស់ និងការទទួលខុសត្រូវនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នសំខាន់ៗ និងការកសាងស្តង់ដាបច្ចេកទេសរួមសម្រាប់ការអនុវត្តនៅតាមក្រសួង ស្ថាប័ន, គន្លឹះជំរុញការអនុវត្តឌីជីថល និងអភិបាលកិច្ចផ្អែកលើទិន្នន័យ។

**វេទិការដ្ឋាភិបាលឌីជីថលកម្ពុជា-កូរ៉េ៖** កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២ **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងមហាផ្ទៃនិងសន្តិសុខ នៃសាធារណរដ្ឋកូរ៉េ** បានសហការរៀបចំ **"វេទិការដ្ឋាភិបាលឌីជីថលកម្ពុជា-កូរ៉េ"** តាមប្រព័ន្ធសន្និសីទវីដេអូ ក្នុងទិសដៅបង្ហាញពីស្ថានភាព និងវឌ្ឍនភាពរដ្ឋាភិបាលឌីជីថលនៅកម្ពុជា ក៏ដូចជាចែករំលែកចំណេះដឹង បទពិសោធ និងឧត្តមានុវត្តន៍របស់រដ្ឋាភិបាលឌីជីថលកូរ៉េ ជូនដល់ក្រសួង ស្ថាប័ន ក្នុងវិស័យសាធារណៈ វិស័យឯកជន និងអង្គការសង្គមស៊ីវិលនៅកម្ពុជា។

**គម្រោង "គាំទ្រកម្ពុជាឌីជីថលសម្រាប់គម្រោងអភិវឌ្ឍន៍ក្របកដោយបរិយាបន្ន" ស្តីពីការសិក្សាគំរូរដ្ឋាភិបាលឌីជីថលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖** រដ្ឋាភិបាលបានដាក់ឱ្យអនុវត្តគម្រោង **"គាំទ្រកម្ពុជាឌីជីថលសម្រាប់គម្រោងអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន" ស្តីពីការសិក្សាគំរូរដ្ឋាភិបាលឌីជីថលនៅថ្នាក់ក្រោមជាតិ** កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ដែលមានការអញ្ជើញចូលរួមពីតំណាងស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា តំណាងធនាគារអភិវឌ្ឍន៍អាស៊ី តំណាងក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ តំណាងដៃគូអភិវឌ្ឍន៍ដូចជា JICA, GIZ, EU តំណាងសមាគមកូរ៉េ NIPA និងក្រុមការងារអនុវត្តគម្រោង។ ការបង្កើតគម្រោងនេះមានគោលបំណងធ្វើការផ្សព្វផ្សាយជូនដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការផ្តល់កិច្ចសហការជាមួយក្រុមការងារគម្រោង ដើម្បីចុះសិក្សាបន្ថែមឱ្យកាន់តែស៊ីជម្រៅ និងប្រមូលធាតុចូលនានា ជាពិសេសការប្រើប្រាស់កម្មវិធី ឬបច្ចេកវិទ្យាផ្សេងៗទៀតដែលបាននិងកំពុងអនុវត្តន៍ សំដៅត្រៀមសម្រាប់គាំទ្រដល់រដ្ឋាភិបាលឌីជីថលនៅកម្ពុជា និងដើម្បីបន្តពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលឱ្យកាន់តែមានប្រសិទ្ធភាព។

**ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន៖** កាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវ «**ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានដំណាក់កាលទី២**» ដោយធុរជនអាចស្នើសុំអាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ប្រកាសបង្កើតតាមអនឡាញ តាមរយៈគេហទំព័រ **www.registrationservices.gov.kh**។ ផតថលរួមនេះនឹងជួយសម្រួលដល់អាជីវករ និងវិនិយោគិន ក្នុងការចុះអាជ្ញាបណ្ណអាជីវកម្ម បង់ពន្ធ និងសាកសួរពីព័ត៌មាននានាទាក់ទងទៅនឹងការធ្វើអាជីវកម្មដែលផ្តល់ភាពងាយស្រួល និងចំណេញពេលវេលា។ លើសពីនេះទៀត ប្រតិបត្តិការស្វ័យប្រវត្តិនៃការទាញយកទិន្នន័យរបស់ក្រុមហ៊ុន/សហគ្រាស ជាសមិទ្ធផលនៃការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈ**ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)**។ ការណ៍នេះមិនត្រឹមតែបង្កើនបទពិសោធន៍នៃការប្រើប្រាស់ឱ្យកាន់តែមានលក្ខណៈងាយស្រួលជាងមុន សម្រាប់ធុរជនក្នុងការបំពេញពាក្យស្នើសុំប៉ុណ្ណោះទេ ប៉ុន្តែក៏ជាបច្ច័យវិជ្ជមានដែលអនុញ្ញាតឱ្យក្រសួង ស្ថាប័នអាចកាត់បន្ថយរយៈពេលត្រួតពិនិត្យពាក្យស្នើសុំ និងធានាបានថាទិន្នន័យរបស់ក្រុមហ៊ុន/សហគ្រាសនៅគ្រប់ក្រសួង ស្ថាប័នមានសង្គតិភាពផងដែរ។

**គេហទំព័រ phnompenh.gov.kh៖** ប្រជាពលរដ្ឋកម្ពុជាអាចទទួលបានសេវាសំខាន់ៗចំនួនប្រមាណ ៩២ ក្នុងវិស័យ ដូចជា វិស័យសុខាភិបាល, វិស័យទេសចរណ៍, វិស័យសាធារណការ និងដឹកជញ្ជូន, វិស័យព័ត៌មាន, វិស័យឧស្សាហកម្ម និងសិប្បកម្ម, វិស័យពាណិជ្ជកម្ម, វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង ជាដើម នៅលើគេហទំព័រសាលារាជធានីភ្នំពេញ phnompenh.gov.kh។

ក្រៅពីនេះ នៅតាមក្រសួងនានាក៏មានផ្តល់ជូននូវសេវាឌីជីថលដល់ប្រជាពលរដ្ឋ ដូចជា ការស្នើសុំទិដ្ឋការនៅលើគេហទំព័រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ mfaic.gov.kh និងការស្នើសុំលិខិតអនុញ្ញាត អាជ្ញាបណ្ណ និងសេវាផ្សេងទៀតរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៅលើគេហទំព័រ service.mptc.gov.kh ព្រមទាំងការចុះបញ្ជីយានយន្ត, ការស្នើសុំការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត, ការស្នើសុំប្រលងយក ឬការប្តូរប័ណ្ណបើកបរ, ការទទួលព័ត៌មានពីសេវាដឹកជញ្ជូនផ្លូវដែក និងផ្លូវទឹក និងការស្នើសុំអាជ្ញាបណ្ណដឹកជញ្ជូន នៅលើគេហទំព័ររបស់ក្រសួងសាធារណការ និងដឹកជញ្ជូន mpwt.gov.kh ជាដើម។

## IV. សន្និដ្ឋាន

ជារួម បដិវត្តន៍ឧស្សាហកម្ម ៤.០ និងវិបត្តិជំងឺកូវីដ-១៩ បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងលើវិស័យអប់រំ, ទីផ្សារការងារ, វិស័យសុខាភិបាល, វិស័យធុរកិច្ច, សេវាសាធារណៈ និងរដ្ឋបាលសាធារណៈជាដើម។ ការប្រើប្រាស់បច្ចេកវិទ្យា ដូចជា បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍, QR Code, ការទូទាត់តាមបែបឌីជីថល, បច្ចេកវិទ្យាកុំព្យូទ័រក្លោដ, ទិន្នន័យធំ និងស្វ័យប្រវត្តិកម្មក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយពង្រឹងការផ្តល់សេវាដល់ប្រជាពលរដ្ឋ និងអាជីវករ, សន្សំសំចៃថវិកា, បង្កើនប្រសិទ្ធភាព និងផលិតភាពការងារ, ពង្រឹងតម្លាភាព និងភាពបើកចំហ និងការពារទិន្នន័យ និងព័ត៌មានសំខាន់របស់រដ្ឋាភិបាល។ ប្រទេសកម្ពុជាមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដោយសារចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត និងបណ្តាញសង្គមមានការកើនឡើងខ្ពស់ ហើយចំនួនយុវជនដែលអាចចាប់យក និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបានលឿន និងអាជីវករដែលចេះទាញយកសក្តានុពលពីបច្ចេកវិទ្យា ព្រមទាំងក្រុមហ៊ុនផ្តល់សេវាបច្ចេកវិទ្យាឌីជីថលមានការកើនឡើងជាលំដាប់។ ហេតុនេះហើយ រាជរដ្ឋាភិបាលបានខិតខំក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល តាមរយៈការបង្កើតនូវគោលនយោបាយ, វេទិការដ្ឋាភិបាលឌីជីថល, គម្រោនានាសម្រាប់គាំទ្រដល់ការអភិវឌ្ឍរដ្ឋាភិបាល និងសេវាតាមប្រព័ន្ធអនឡាញជាដើម។ ប៉ុន្តែទន្ទឹមនឹងនេះ រដ្ឋាភិបាលក៏គួរបន្តគិតគូរលើការអភិវឌ្ឍធនធានមនុស្ស, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការការពារសន្តិសុខឌីជីថលនៅតាមក្រសួងស្ថាប័ន ដើម្បីអាចជំរុញដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថបន្ថែមទៀត។ មិនតែប៉ុណ្ណោះ ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលនេះមិនមែនជាទំនួលខុសត្រូវរបស់រដ្ឋាភិបាលទាំងស្រុងទេ ពោលគឺប្រជាពលរដ្ឋក៏ត្រូវចេះបង្កើនសមត្ថភាពឌីជីថលរបស់ខ្លួន ដើម្បីអាចទាញយកផលប្រយោជន៍បានពេញលេញពីសេវាឌីជីថល។

## ឯកសារយោង


- 2020 United Nations E-Government Survey, ចេញផ្សាយថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០២២, ចូលអានថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០២២, https://www.un.org/development/desa/publications/publication/2020-united-nations-e-government-survey
- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ , ចេញផ្សាយថ្ងៃទី ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១, ចូលអានថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០២២, https://www.mcs.gov.kh/?p=34022
- គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ , ចេញផ្សាយថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២, ចូលអានថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២២, https://mptc.gov.kh/documents/%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99/27902/
- DIGITAL 2022: CAMBODIA, ចេញផ្សាយថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០២២, ចូលអានថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២២, https://datareportal.com/reports/digital-2022-cambodia
- Digital Government Transformation, ចូលអានថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២២, https://granicus.com/dictionary/digital-government-transformation/
- E-Government Implementation, ចេញផ្សាយខែមករា ឆ្នាំ២០១៦, ចូលអានថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២២, https://www.researchgate.net/publication/309024557_E-Government_Implementation
- How Data-Driven Technology Can Upgrade Cambodia's E-government, , ចូលអានថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២២, https://www.kas.de/documents/264850/7993338/Chapter+9.pdf/39084bee-3b38-3973-dcf6-e91c539a048b?t=1579754549758
- Advantages and Disadvantages of E-Governance, ចេញផ្សាយថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០២០, ចូលអានថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២២, https://www.legalwiz.in/blog/advantages-and-disadvantages-of-e-governance
- គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ , ចេញផ្សាយថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២, ចូលអានថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២២, https://mptc.gov.kh/documents/%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99/27902/
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សហការជាមួយក្រសួងមហាផ្ទៃ និងសន្តិសុខនៃសាធារណរដ្ឋកូរ៉េ រៀបចំវេទិការរដ្ឋាភិបាលឌីជីថលកម្ពុជា-កូរ៉េ , ចេញផ្សាយថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២, ចូលអានថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២២, https://mptc.gov.kh/news/%E1%9E%9F%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98%E1%9E%97%E1%9E%B6%E1%9E%96%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%9F%E1%9E%BD%E1%9E%84/29585/
- ពិធីសម្ពោធដាក់ឱ្យអនុវត្តគម្រោង "គាំទ្រកម្ពុជាឌីជីថលសម្រាប់គម្រោងអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន ស្តីពីការសិក្សាគំរូរដ្ឋាភិបាលឌីជីថលនៅថ្នាក់ក្រោមជាតិ" , ចេញផ្សាយថ្ងៃទី ២៨ ខែកក្កដា ២០២១ចូលអានថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២២, https://ncdd.gov.kh/news-kh/d-government/

- រដ្ឋាភិបាលឌីជីថលនៅកម្ពុជា, កម្មវិធី ជជែកពីកម្ពុជា ៤.០, វាគ្មិនកិត្តិយស លោក ស៊ុន វ៉ាពីដ អគ្គនាយករងនៃ អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ផ្សាយផ្ទាល់កាលពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២២

---

www.cambodia4point0.org

កម្ពុជា ៤.០ - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.០ Cambodia 4.0

កម្ពុជា ៤.០ - Cambodia 4.0

កម្ពុជា ៤.០ - Cambodia 4.0

កម្ពុជា ៤.០ - Cambodia 4.0

Cambodia 4.0 Center